**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ២៨៦......សហវ.ប្រក

**ប្រកាសអន្តរក្រសួង**

**ស្តីពី**

**ការបង្កើតរជ្ជទេយ្យបុរេប្រទានសម្រាប់ឆ្នាំ២០១៦**

**របស់អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន**

**នៃក្រសួងបរិស្ថាន**

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គនាយក**

**អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រមក/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បកចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញប្រកាសលេខ ៤៧៦ ប្រ.ក ប.ស្ត ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការតែងតាំងមន្ត្រីអង្គភាពថវិកា

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St. 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរសព្ទ័ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញប្រកាសលេខ ៥៤២ ប្រក.បស្ត ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការតែងតាំងអាណាប័កផ្ទេរសិទ្ធិនិងការផ្ទេរតំណាទានថវិកា
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៩៣៧ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន។

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទានជំពូក៦០ "ការទិញ" និងជំពូក៦១ "សេវាកម្ម" នៅអគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន នៃក្រសួងបរិស្ថាន សម្រាប់មុខចំណាយដូចមានចែងក្នុងប្រការ៥ ថ្មី នៃប្រកាសលេខ ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ២.-**

ចំនួនទឹកប្រាក់មួយជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ដូចតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា ប្រធាននាយករដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៤ ខែឧសភាឆ្នាំ២០១៦

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**អគ្គនាយក**
**អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន**

**បណ្ឌិត គាង សុទុទ្ធី**

កន្លែងទទួល៖
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមុខងារសាធារណៈ
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៤
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានថវិកាកម្មវិធីឆ្នាំ២០១៦
របស់អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន នៃក្រសួងបរិស្ថាន

ឯកតា:គិតជារៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៦ | ឥណទានដែលត្រូវជ្រើសរើស | ឥណទានជ្រើសយកបុរេប្រទាន | ឥណទានទូទាត់ធម្មតា | ឥណទាន០១ជុំបង្វិលជ្រើសយកបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៤ជុំ | ៦=៣/២ |
| | | | សរុប | 1,099,400,000 | 1,019,400,000 | 407,860,000 | 611,540,000 | 101,965,000 | 40.01% |
| 60 | | | ការទិញ | 246,500,000 | 246,500,000 | 69,380,000 | 177,120,000 | 17,345,000 | 28.15% |
| | 6001 | | សម្ភារៈផ្គត់ផ្គង់ថែទាំ | 0 | 0 | 0 | 0 | 0 | #DIV/0! |
| | | 60011 | សម្ភារៈផ្គត់ផ្គង់សម្អាតនិងអនាម័យ | 0 | 0 | 0 | 0 | 0 | #DIV/0! |
| | | 60015 | ប្រេងឥន្ធនៈនិងប្រេងរំអិល | 0 | 0 | 0 | 0 | 0 | #DIV/0! |
| | 6002 | | សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល | 246,500,000 | 246,500,000 | 69,380,000 | 177,120,000 | 17,345,000 | 28.15% |
| | | 60021 | សម្ភារៈការិយាល័យនិងការបោះពុម្ព | 246,000,000 | 246,000,000 | 68,880,000 | 177,120,000 | 17,220,000 | 28.00% |
| | | 60022 | សៀវភៅមើលនិងឯកសារ | 500,000 | 500,000 | 500,000 | 0 | 125,000 | 100.00% |
| | 6005 | | សម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារ | 0 | 0 | 0 | 0 | 0 | #DIV/0! |
| | | 60052 | សង្ហារឹម | 0 | 0 | 0 | 0 | 0 | #DIV/0! |
| 61 | | | សេវាកម្ម | 852,900,000 | 772,900,000 | 338,480,000 | 434,420,000 | 84,620,000 | 43.79% |
| | 6102 | | ការជួលមធ្យោបាយដឹកជញ្ជូន | 40,000,000 | 40,000,000 | 5,600,000 | 34,400,000 | 1,400,000 | 14.00% |
| | 6107 | | សោហ៊ុយសិក្សាពិសោធន៍ សោហ៊ុយនៃការប្រើប្រាស់សៅនិងសោហ៊ុយនៃការប្រើប្រាស់សិទ្ធិ | 80,000,000 | 0 | 0 | 0 | 0 | #DIV/0! |
| | | 61073 | សោហ៊ុយនៃការប្រើប្រាស់សិទ្ធិ | 80,000,000 | 0 | 0 | 0 | 0 | #DIV/0! |
| | 6110 | | ទំនាក់ទំនងសាធារណៈនិងផ្សព្វផ្សាយ | 477,000,000 | 477,000,000 | 196,050,000 | 280,950,000 | 49,012,500 | 41.10% |
| | | 61103 | ប្រជុំ សិក្ខាសាលា និងសន្និសីទ | 147,000,000 | 147,000,000 | 110,250,000 | 36,750,000 | 27,562,500 | 75.00% |
| | | 61107 | ការឃោសនានិងផ្សព្វផ្សាយព័ត៌មានសាធារណៈ | 330,000,000 | 330,000,000 | 85,800,000 | 244,200,000 | 21,450,000 | 26.00% |
| | 6112 | | ចំណាយខូទាត់សោហ៊ុយក្នុងប្រទេស | 164,000,000 | 164,000,000 | 89,730,000 | 74,270,000 | 22,432,500 | 54.71% |
| | | 61121 | សោហ៊ុយដឹកជញ្ជូន | 55,000,000 | 55,000,000 | 39,050,000 | 15,950,000 | 9,762,500 | 71.00% |
| | | 61122 | សោហ៊ុយបេសកកម្ម | 34,000,000 | 34,000,000 | 17,680,000 | 16,320,000 | 4,420,000 | 52.00% |
| | | 61123 | សោហ៊ុយស្នាក់នៅ | 75,000,000 | 75,000,000 | 33,000,000 | 42,000,000 | 8,250,000 | 44.00% |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 6113 | | ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស | 90,000,000 | 90,000,000 | 45,200,000 | 44,800,000 | 11,300,000 | 50.22% |
| | 61131 | សោហ៊ុយដឹកជញ្ជូន | 15,000,000 | 15,000,000 | 4,950,000 | 10,050,000 | 1,237,500 | 33.00% |
| | 61132 | សោហ៊ុយបេសកកម្ម | 55,000,000 | 55,000,000 | 30,250,000 | 24,750,000 | 7,562,500 | 55.00% |
| | 61133 | សោហ៊ុយស្នាក់នៅ | 20,000,000 | 20,000,000 | 10,000,000 | 10,000,000 | 2,500,000 | 50.00% |
| 6114 | | សោហ៊ុយប្រៃសណីយ៍និងទូរគមនាគមន៍ | 1,900,000 | 1,900,000 | 1,900,000 | 0 | 475,000 | 100.00% |
| | 61141 | សោហ៊ុយប្រៃសណីយ៍ | 1,900,000 | 1,900,000 | 1,900,000 | 0 | 475,000 | 100.00% |

បានឃើញ និងពិនិត្យត្រឹមត្រូវ
ភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០១៦
ស. អគ្គនាយក
អគ្គនាយកដ្ឋានរតនាគារជាតិ
អគ្គនាយករង

ម៉ៅ បានសុវណ្ណអានីថាស៊ីលា

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៦
ប្រធានក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ
អមក្រសួងបរិស្ថាន

ពៅ_ម៉េងហ៊ាង

បានឃើញ និងពិនិត្យត្រឹមត្រូវ
ភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០១៦
ប្រធាននាយកដ្ឋានផែនការ រដ្ឋបាល និងហិរញ្ញវត្ថុ

ចន់_វណ្ណារិទ្ធ

ភ្នំពេញ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ២០១៦
រដ្ឋលេខាធិការប្រចាំការ

បានឃើញ និងឯកភាព
ភ្នំពេញ ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ២០១៦
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន

បានឃើញ និងឯកភាព
ភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០១៦
អគ្គនាយកចំណេះដឹង និងព័ត៌មានបរិស្ថាន

បណ្ឌិត សាវ សុវិទ្ធី